PESTECH

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីជូនដំណឹង
## ស្តីពី
## កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញ របស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក

សូមជម្រាបជូនដំណឹងថា ដោយអនុលោមតាមសេចក្តីសម្រេចក្រុមប្រឹក្សាភិបាល ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ បានសម្រេចលើកិច្ចប្រជុំមហាសន្និបាទភាគហ៊ុនិករបស់ **ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក ("ផថខ")** នឹងប្រព្រឹត្តនៅ **ថ្ងៃសុក្រ ១០ ធ្នូ ២០២១ នៅម៉ោង ១០:០០ ព្រឹក**។ កិច្ចប្រជុំនឹងរៀបចំឡើងដោយប្រតិបត្តិតាម គោលនយោបាយ កូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា ត្រូវរក្សាកម្លាតដែលបានកំណត់ដោយអាជ្ញាធរមានសម្ថកិច្ច។ អ្នកចូលរួមគ្រប់រូបនឹងត្រូវមានការវាស់សីតុណ្ហភាពមុនចូលបន្ទប់ប្រជុំ។

របៀបវារៈលម្អិតនៃកិច្ចប្រជុំមានដូចខាងក្រោម៖

| | | |
|---|---|---|
| កាលបរិច្ឆេទសម័យប្រជុំ | ៖ | ថ្ងៃសុក្រ ១០ ធ្នូ ២០២១ |
| កាលបរិច្ឆេទកំណត់ទុក | ៖ | ថ្ងៃពុធ ១៧ វិច្ឆិកា ២០២១ |
| ទីកន្លែងប្រជុំ | ៖ | បន្ទប់ប្រជុំភូគីត្រា ១ សណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា 26 Old August site មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ |

| កាលវេលា | របៀបវារៈ |
|---|---|
| ៩:០០ ព្រឹក - ១០:០០ ព្រឹក | ការចុះវត្តមានភាគហ៊ុនិក |
| | ការបង្ហាញអំពីរបៀបវារៈនៃកិច្ចប្រជុំ និងបទបង្ហាញស្តីពីដំណើរការនៃការបោះឆ្នោត |
| ១០:០០ ព្រឹក - ១០:១៥ ព្រឹក | មតិស្វាគមន៍ដោយ លោក Paul Lim Pay Chuan ប្រធានក្រុមប្រឹក្សាភិបាលនៃ **ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក** |
| | របាយការណ៍សមិទ្ធផលអាជីវកម្មប្រចាំឆ្នាំគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ |
| | សំណួរ និងចម្លើយ |

**ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក** (លេខចុះបញ្ជី៖ ០០០០០៩៥៧)

(ក្រុមហ៊ុន PESTECH)

ផ្ទះលេខ ០៦ ផ្លូវ ៥៨៨ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨២ ១០៥ ទូរសារ +៨៥៥ ២៣ ៨៨២ ១០៦ គេហទំព័រ៖ www.pestech-international.com

PESTECH

| | | |
|---|---|---|
| ១០:១៥ ព្រឹក - ១១:០០ ព្រឹក | **ការអនុម័តលើសេចក្ដីសម្រេច** | |
| | សេចក្ដីសម្រេច ១ | ការអនុម័តលើលាភការរបស់ក្រុមប្រឹក្សាភិបាល |
| | សេចក្ដីសម្រេច ២ | ការអនុម័តលើការបន្តអណត្តិ លោក Paul Lim Pay Chuan ជាប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិជាថ្មី ដោយអនុលោមតាមមាត្រា ១៨.១ នៃលក្ខន្តិកៈក្រុមហ៊ុន |
| | សេចក្ដីសម្រេច ៣ | ការអនុម័តលើការបន្តអណត្តិ លោក Lim Ah Hock ជាអភិបាលប្រតិបត្តិជាថ្មី ដោយអនុលោមតាមមាត្រា ១៨.១ នៃលក្ខន្តិកៈក្រុមហ៊ុន |
| | សេចក្ដីសម្រេច ៤ | ការអនុម័តលើការបន្តអណត្តិ លោក Han Fatt Juan ជាអភិបាលប្រតិបត្តិជាថ្មី ដោយអនុលោមតាមមាត្រា ១៨.១ នៃលក្ខន្តិកៈក្រុមហ៊ុន |
| | សេចក្ដីសម្រេច ៥ | ការអនុម័តលើការបន្តអណត្តិ លោក Charles Tan Pu Hooi ជាអភិបាលប្រតិបត្តិជាថ្មី ដោយអនុលោមតាមមាត្រា ១៨.១ នៃលក្ខន្តិកៈក្រុមហ៊ុន |
| | សេចក្ដីសម្រេច ៦ | ការអនុម័តលើការបែងចែកភាគលាភ ចំនួន ០,០០៦៥ ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២១ |
| | សេចក្ដីសម្រេច ៧ | ការអនុម័តលើសិទ្ធិប្រកាសបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទដែលនឹងបញ្ចប់គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ |
| | សេចក្ដីសម្រេច ៨ | សិទ្ធិក្នុងការបោះផ្សាយភាគហ៊ុនដោយយោងតាមលក្ខន្តិកៈក្រុមហ៊ុន<br>"***សម្រេចថា*** កម្មវត្ថុដែលនៅតែមានចំពោះច្បាប់សហគ្រាសពាណិជ្ជកម្ម លក្ខន្តិកៈក្រុមហ៊ុន និងការឯកភាពពីនិយ័តករមូលបត្រកម្ពុជា ("នមក") ផ្សារមូលបត្រកម្ពុជា ("ផមក") រដ្ឋាភិបាល និង/ឬអាជ្ញាធរពាក់ព័ន្ធផ្សេងៗ តាមរយៈនេះអភិបាលដែលបានទទួលសិទ្ធស្របច្បាប់ សូមចេញ និងបែងចែកភាគហ៊ុននៅក្នុងដើមទុនរបស់ក្រុមហ៊ុនពីមួយគ្រាទៅមួយគ្រានូវតម្លៃណាមួយ និងយោងទៅតាមលក្ខខណ្ឌនានាសម្រាប់គោលបំណងផ្សេងៗ និងចំពោះបុគ្គលម្នាក់ ឬច្រើនណាក៏ដោយ អភិបាលអាចមានសិទ្ធសម្រេចតាមឆន្ទានុសិទ្ធិសមស្របទាំងស្រុងរបស់ពួកគាត់ |

PESTECH

| | | |
|---|---|---|
| | | ***និងសម្រេចថា*** អភិបាលក៏ត្រូវបានផ្តល់នូវសិទ្ធអំណាចផងដែរដើម្បីទទួលបាននូវការអនុម័តចំពោះការលក់មូលបត្រភាគហ៊ុន និងការដាក់តម្លៃភាគហ៊ុនបន្ថែម ក៏ដូចជាការចេញលក់នៅលើ ផមក ផងដែរ។<br>***និងសម្រេចបន្ថែមថា*** ការផ្តល់សិទ្ធអំណាចនេះ នឹងចាប់ផ្តើមសម្រេចភ្លាមៗដោយយោងតាមការអនុម័តនៃសេចក្តីសម្រេចនេះ និងបន្តអនុវត្តរហូតដល់កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិករបស់ក្រុមហ៊ុននាពេលក្រោយ” |
| | សេចក្តីសម្រេច ៩ | ការអនុម័តលើការប្តូរអាសយដ្ឋានចុះបញ្ជីការិយាល័យក្រុមហ៊ុន |
| | សេចក្តីសម្រេច ១០ | ការអនុម័តលើការធ្វើវិសោធនកម្មលើលក្ខន្តិកៈក្រុមហ៊ុន ដោយលុបចោលមាត្រាចាស់ទាំងស្រុង និងរំលេចនូវមាត្រាថ្មី ព័ត៌មានលម្អិតមានភ្ជាប់ជូននូវឧបសម្ព័ន្ធ ក។ |
| | **ដំណើរការបោះឆ្នោត និងលទ្ធផលបោះឆ្នោត** | |
| ១១:៥០ ព្រឹក - ១២:៣០ ព្រឹក | ប្រមូលសន្លឹកឆ្នោត | |
| | សម្រាកទទួលទានកាហ្វេ | |
| | ការប្រកាសលទ្ធផលបោះឆ្នោត | |
| | បញ្ចប់កិច្ចប្រជុំ | |

**កំណត់សម្គាល់នៃការពន្យល់សេចក្តីសម្រេច៖**

**សេចក្តីសម្រេច ១ - អនុម័តលើលាភការនៃក្រុមប្រឹក្សាភិបាល**

សេចក្តីសម្រេចនេះ ត្រូវបានដាក់លើការអនុម័តលាភការរបស់ក្រុមប្រឹក្សាភិបាលដែលរួមទាំងអភិបាលប្រតិបត្តិចំនួន ៤ រូប និងអភិបាលឯករាជ្យចំនួន ១ រូប សម្រាប់រយៈពេលចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

**សេចក្តីសម្រេច ២ ដល់ ៥ - ការអនុម័តលើការបន្តអណត្តិអភិបាលប្រតិបត្តិជាថ្មី**

សេចក្តីសម្រេចនេះត្រូវរៀបចំឡើងដើម្បីអនុម័តលើការបន្តអណត្តិជាថ្មីរបស់អភិបាលដូចខាងក្រោមដោយអនុលោមតាមមាត្រា ១៨.១ នៃលក្ខន្តិកៈក្រុមហ៊ុន។

- លោក Paul Lim Pay Chuan ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ
- លោក Lim Ah Hock អភិបាលប្រតិបត្តិ
- លោក Han Fatt Juan អភិបាលប្រតិបត្តិ/ប្រធាននាយកប្រតិបត្តិ

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក (លេខចុះបញ្ជី៖ ០០០០០៩៥៧)
(ក្រុមហ៊ុន PESTECH)
ផ្ទះលេខ ០៦ ផ្លូវ ៥៨៨ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨២ ១០៥ ទូរសារ +៨៥៥ ២៣ ៨៨២ ១០៦ គេហទំព័រ៖ www.pestech-international.com

PESTECH

- លោក Charles Tan Pu Hooi អភិបាលប្រតិបត្តិ

**សេចក្តីសម្រេច ៦ - ការអនុម័តលើការបែងចែកភាគលាភ ចំនួន ០,០០៦៥ ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១**

នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ ក្រុមហ៊ុនបានប្រកាសថា ក្រុមប្រឹក្សាភិបាលបានកំណត់ និងប្រកាសភាគលាភ ចំនួន 0.00៦៥ ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុនសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។ ភាគលាភអាចនឹងមានការផ្លាស់ប្តូរស្របតាមលទ្ធផលសវនកម្មរបស់សវនករឯករាជ្យ និងសេចក្តីសម្រេចនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក។

**សេចក្តីសម្រេច ៧ - ការអនុម័តលើការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទដែលនឹងបញ្ចប់គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២**

ស្របតាមគោលនយោបាយភាគលាភ ក្រុមហ៊ុនមានបំណងបែងចែកភាគលាភអប្បបរមាចំនួន (៣០%) នៃប្រាក់ចំណេញរបស់ខ្លួនបន្ទាប់ពីកាត់ពន្ធរួចដោយយោងទៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍សាច់ប្រាក់ ប្រាក់ចំណេញរក្សាទុកចំណាយមូលធន និងកត្តាផ្សេងទៀតដែលក្រុមប្រឹក្សាភិបាលគិតថាជាប់ពាក់ព័ន្ធ។

ក្រុមហ៊ុនសម្ព័ន្ធអាចពិចារណាបែងចែកភាគលាភជាសាច់ប្រាក់ ជាភាគហ៊ុនសម្រាប់ឱកាសវិនិយោគឡើងវិញនៅក្នុងក្រុមហ៊ុន ឬជម្រើសទាំងពីររួមគ្នា។

សេចក្តីសម្រេចនេះ ប្រសិនបើបានអនុម័តនឹងអនុញ្ញាតឱ្យក្រុមប្រឹក្សាភិបាលស្នើសុំ និងប្រកាសភាគលាភពីមួយគ្រាទៅមួយគ្រាតាមអត្រា និងល័ក្ខខ័ណ្ឌដូចដែលក្រុមប្រឹក្សាភិបាលអាចសំរេចតាមឆន្ទានុសិទ្ធិសមស្របទាំងស្រុងរបស់ពួកគាត់។ តាមរយៈការផ្តល់សិទ្ធនេះ លុះត្រាតែក្រុមហ៊ុនលុបចោល ឬផ្លាស់ប្តូរក្នុងកិច្ចប្រជុំមហាសន្និបាទ នោះនឹងត្រូវផុតកំណត់នៅពេលបញ្ចប់កិច្ចប្រជុំមហាសន្និបាទម្ចាស់ភាគហ៊ុនិករបស់ក្រុមហ៊ុននាពេលក្រោយ។

**សេចក្តីសម្រេច ៨ - សិទ្ធិក្នុងការចេញភាគហ៊ុនដោយយោងតាមលក្ខន្តិកៈក្រុមហ៊ុន**

សេចក្តីសម្រេចដែលបានស្នើសុំ ប្រសិនបើបានឆ្លងការសម្រេច ផ្តល់លភាពងាយស្រួលដល់អភិបាលដើម្បីចេញភាគហ៊ុនសកម្មភាពរួមជាអាទ៍ ការដាក់ភាគហ៊ុនសម្រាប់ការផ្តល់មូលនិធិគម្រោងវិនិយោគនាពេលអនាគតរបស់ក្រុមហ៊ុន ការវិនិយោគ និង/ឬ ការទិញភាគហ៊ុនតាមរយៈ ការចេញភាគហ៊ុននៅក្នុងក្រុមហ៊ុនចំពោះបុគ្គលនៅពេលណាក៏បានតាមដែលអភិបាលចាត់ទុកថាសមស្របដោយមិនចាំបាច់មានការកោះប្រជុំទូទៅ។ តាមរយៈសិទ្ធិអំណាចនេះ លុះត្រាតែក្រុមហ៊ុនបានលុបចោល ឬផ្លាស់ប្តូរក្នុងកិច្ចប្រជុំមហាសន្និបាទ នោះនឹងត្រូវផុតកំណត់នៅពេលបញ្ចប់កិច្ចប្រជុំមហាសន្និបាទម្ចាស់ភាគហ៊ុនិករបស់ក្រុមហ៊ុននាពេលក្រោយ។

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក (លេខចុះបញ្ជី៖ ០០០០០៩៥៧)
(ក្រុមហ៊ុន PESTECH)
ផ្ទះលេខ ០៦ ផ្លូវ ៥៨៨ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨២ ១០៥ ទូរសារ +៨៥៥ ២៣ ៨៨២ ១០៦ គេហទំព័រ៖ www.pestech-international.com

PESTECH

**សេចក្តីសម្រេច ៩ -  ការអនុម័តលើការប្តូរអាសយដ្ឋានចុះបញ្ជីការិយាល័យក្រុមហ៊ុន**

ការស្នើសុំលើការប្តូរអាសយដ្ឋានទីតាំងចុះបញ្ជីការិយាល័យរបស់ក្រុមហ៊ុនទៅ ជាន់ទី ១០ អាគារលេខ ៣៥ មហាវិថីម៉ៅសេទុង ភូមិ៦ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ស្របតាមភការលូតលាស់ និងភាពរីកចម្រើនរបស់ក្រុមហ៊ុន។

**សេចក្តីសម្រេច ១០ -  ការអនុម័តលើការធ្វើវិសោធនកម្មលើលក្ខន្តិកៈក្រុមហ៊ុនដោយលុបចោលមាត្រាចាស់ទាំងស្រុង និងរំលេចនូវមាត្រាថ្មី សម្រាប់ព័ត៌មានលម្អិតមានភ្ជាប់ជូននូវឧបសម្ព័ន្ធ ក។**

ការស្នើសុំធ្វើការកែប្រែលក្ខន្តិកៈក្រុមហ៊ុនគឺមានបំណងធ្វើបច្ចុប្បន្នភាពលើកម្មវត្ថុអាជីវកម្ម អាសយដ្ឋានចុះបញ្ជីការិយាល័យរបស់ក្រុមហ៊ុន ធ្វើបច្ចុប្បន្នភាពបញ្ញត្តិពាក់ព័ន្ធលើការលក់មូលបត្រភាគហ៊ុនរបស់ ផថខ ក៏ដូចជាសម្រួលដល់ការប្រើប្រាស់អេឡិចត្រូនិចសម្រាប់ដំណើរការកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងម្ចាស់ភាគហ៊ុនិក។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១

**ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក**

ព្រះរាជាណាចក្រកម្ពុជា
ផេសថិក
(ខេមបូឌា) ម.ក
PESTECH (CAMBODIA)
PLC
KINGDOM OF CAMBODIA

## ឧបសម្ព័ន្ធ ក

| មាត្រា | ចាស់ | ថ្មី |
|---|---|---|
| ២ | **កម្មវត្ថុអាជីវកម្ម**<br>គោលបំណង និងកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន មានៈ<br>៤២២ សំណង់នៃគម្រោងសេវាកម្មសាធារណៈ<br>៤២២០២ សំណង់គម្រោងសេវាកម្មអគ្គីសនី និង ទូរគមនាគមន៍ | **កម្មវត្ថុអាជីវកម្ម**<br>គោលបំណង និងកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន មានៈ<br>៤២២ សំណង់នៃគម្រោងសេវាកម្មសាធារណៈ<br>៤២២០២ សំណង់គម្រោងសេវាកម្មអគ្គីសនី និង ទូរគមនាគមន៍<br>**៨២៩ សកម្មភាពសេវាកម្មគាំទ្រដល់អាជីវកម្ម ដទៃទៀតដែលពុំបានរាប់បញ្ចូល**<br>**៨២៩៩០ សកម្មភាពសេវាកម្មគាំទ្រដល់អាជីវកម្ម ដទៃទៀតដែលពុំបានរាប់បញ្ចូល**<br>**៤៣២ សកម្មភាពដំឡើងប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក និងសកម្មភាពដំឡើងផ្សេងៗទៀត**<br>**៤៣២១០ ការដំឡើងប្រព័ន្ធអគ្គិសនី** |
| ៥ | **ការិយាល័យចុះបញ្ជី**<br>៥.១ អាសយដ្ឋានចុះបញ្ជី និងការដ្ឋានវិនិយោគ របស់ក្រុមហ៊ុនស្ថិតនៅ ផ្ទះលេខ៦ ផ្លូវ៥៨៨ សង្កាត់បឹងកក់ ២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | **ការិយាល័យចុះបញ្ជី**<br>៥.១ អាសយដ្ឋានចុះបញ្ជី និងការដ្ឋានវិនិយោគ របស់ក្រុមហ៊ុនស្ថិតនៅ ជាន់ទី១០ អាគារលេខ ៣៥ មហាវិថីម៉ៅសេទុង ភូមិ៦ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| ៧ | **ដើមទុនចុះបញ្ជី**<br>ចំនួនភាគហ៊ុនសរុបដែលក្រុមហ៊ុនអនុញ្ញាតអោយបោះចេញ គឺ ៧១.០០០.០០០ (ចិតសិបមួយលាន ) ភាគហ៊ុនដែលមានតម្លៃចារឹកលើប័ណ្ណសម | **ដើមទុនចុះបញ្ជី**<br>ចំនួនភាគហ៊ុនសរុបដែលក្រុមហ៊ុនអនុញ្ញាតអោយបោះចេញ គឺ **៧៤.៩៤៥.០០០ (ចិតសិបបួនលាន ប្រាំបួនរយសែសិបប្រាំពាន់**) ភាគហ៊ុនដែល |

| | | |
|---|---|---|
| | មូលជាទឹកប្រាក់ចំនួន ០.១០ (ដប់សេន) ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន (គឺស្មើនឹង ៤០០ (បួនរយ) រៀល នៅកាលបរិច្ឆេទចុះហត្ថលេខាលើលក្ខន្តិកៈនេះ) (**"ភាគហ៊ុនធម្មតា"**)។ លើកលែងតែមានបញ្ញត្តិចែងផ្សេងស្របតាមលក្ខន្តិកៈនេះ ភាគហ៊ុនធម្មតាមានសិទ្ធិបោះឆ្នោតគ្មានដែនកំណត់ ដោយភាគហ៊ុននីមួយៗត្រូវមានសិទ្ធិទទួលបានសន្លឹកឆ្នោតមួយសន្លឹក និងសិទ្ធិទទួលបានទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនតាមសមាមាត្រនៃចំណែករៀងៗខ្លួន | មានតម្លៃចារឹកលើប័ណ្ណសមមូលជាទឹកប្រាក់ចំនួន ០.១០ (ដប់សេន) ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន (គឺស្មើនឹង ៤០០ (បួនរយ) រៀល នៅកាលបរិច្ឆេទចុះហត្ថលេខាលើលក្ខន្តិកៈនេះ) (**"ភាគហ៊ុនធម្មតា"**)។ លើកលែងតែមានបញ្ញត្តិចែងផ្សេងស្របតាមលក្ខន្តិកៈនេះ ភាគហ៊ុនធម្មតាមានសិទ្ធិបោះឆ្នោតគ្មានដែនកំណត់ដោយភាគហ៊ុននីមួយៗត្រូវមានសិទ្ធិទទួលបានសន្លឹកឆ្នោតមួយសន្លឹក និងសិទ្ធិទទួលបានទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនតាមសមាមាត្រនៃចំណែករៀងៗខ្លួន |
| ១១ | **វិញ្ញាបនបត្រភាគហ៊ុន**<br><br>បុគ្គលគ្រប់រូបដែលត្រូវបានចុះឈ្មោះជាសមាជិកនៃការចុះបញ្ជីភាគហ៊ុន ត្រូវមានសិទ្ធិដោយមិនបាច់បង់ប្រាក់ ដើម្បីនឹងទទួលបាននៅក្នុងរយៈពេលពីរខែក្រោយពីការបែងចែក ឬការផ្ទេរ (ឬនៅក្នុងរយៈពេលផ្សេងទៀតបែបនេះតាមលក្ខខណ្ឌនៃបោះពុម្ពភាគហ៊ុន ដែលត្រូវផ្តល់ឱ្យវិញ្ញាបនបត្រមួយសម្រាប់ភាគហ៊ុនគ្រប់ថ្នាក់ទាំងអស់ដែលខ្លួនជាអ្នកកាន់កាប់ ឬបន្ទាប់ពីបានបង់ថ្លៃចំណាយសមស្របដូចដែលក្រុមប្រឹក្សាភិបាលអាចសម្រេចនៅពេលម្តងម្កាលសម្រាប់រាល់វិញ្ញាបនបត្រក្រោយពីមានវិញ្ញាបនបត្រទីមួយ វិញ្ញាបនបត្រមួយចំនួនច្រើនទៀតដែលវិញ្ញាបនបត្រនីមួយៗគឺសំរាប់មួយភាគហ៊ុន ឬសំរាប់ភាគហ៊ុនចំនួនច្រើនរបស់ខ្លួន។ នៅទីកន្លែងណាដែលសមាជិកមានចំណែកផ្ទេរនៃភាគហ៊ុនដែលខ្លួនមានភាគហ៊ុនកាន់កាប់សមាជិករូបនោះត្រូវមានសិទ្ធិទទួលបានវិញ្ញាបនបត្រមួយសំរាប់ជាសមតុល្យនៃ | **វិញ្ញាបនបត្រភាគហ៊ុន**<br><br>យោងតាមបញ្ញត្តិពាក់ព័ន្ធ ក្រុមហ៊ុនត្រូវបែងចែក ឬចេញមូលបត្រ និងជូនដំណឹងអំពីការបែងចែក ទៅឱ្យភាគហ៊ុនិកដែលទទួលបានជោគជ័យ និងដាក់ពាក្យស្នើសុំជេញថ្លៃលើមូលបត្រទាំងនោះតាមកាលកំណត់ ឬបានអនុញ្ញាតដោយនិយ័តករ។<br><br>ក្រុមហ៊ុនត្រូវចេញ និងប្រគល់ប្រាក់បញ្ញើមូលបត្រនូវវិញ្ញាបនបត្រសមស្របដូចមាននៅក្នុងបញ្ជីឈ្មោះដែលបានបញ្ជាក់ដោយអ្នកដាក់ប្រាក់បញ្ញើមូលបត្របានចុះឈ្មោះក្នុងនាមជាអ្នកដាក់ប្រាក់បញ្ញើ ឬអ្នកតំណាងរបស់ក្រុមហ៊ុន។<br><br>រាល់វិញ្ញាបនប័ត្រដែលត្រូវចេញ និងមានហត្ថលេខា ឬហត្ថលេខាស្វ័យប្រវត្តិថតចម្លង ឬមធ្យោបាយមេកានិចផ្សេងទៀត និងត្រូវបានចុះហត្ថលេខាដោយអនុលោមតាមលក្ខន្តិកៈក្រុមហ៊ុន និងត្រូវបញ្ជាក់ពី |

PESTECH

| | | |
|---|---|---|
| | ការកាន់កាប់ភាគហ៊ុនដោយមិនគិតថ្លៃឡើយ។ រាល់វិញ្ញាបនបត្រភាគហ៊ុនត្រូវចេញឱ្យដោយមានប្រថាប់ត្រា និងត្រូវដាក់បញ្ជាក់អំពីចំនួន និងថ្នាក់នៃភាគហ៊ុនដែលមាន និងអំពីចំនួនប្រាក់ដែលមិនទាន់បានបង់នៅលើវិញ្ញាបនបត្រភាគហ៊ុននោះ និង (អនុលោមតាមដូចមានចែងចាប់ពីពេលនេះតទៅ) ត្រូវមានចុះហត្ថលេខាដោយផ្ទាល់ដៃយ៉ាងតិចពីអភិបាលម្នាក់ប្រសិនបើតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលអាចកំណត់យកហត្ថលេខាបែបនេះ ឬយកហត្ថលេខាណាមួយដែលត្រូវបានអនុញ្ញាតឱ្យ ឬត្រូវបានចុះហត្ថលេខាពីសំណាក់បុគ្គលផ្សេងទៀតតាមដែលអាចត្រូវបានអនុញ្ញាតឱ្យពីក្រុមប្រឹក្សាភិបាលក្តី ឬតាមវិធីសាស្ត្រ ឬប្រព័ន្ធហត្ថលេខា អេឡិចត្រូនិច។ | **ចំនួន និងថ្នាក់មូលបត្រដែលពាក់ព័ន្ធ និងចំនួនបានបង់ប្រាក់នោះ។** |
| ២០ | **កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល**<br><br>ការបញ្ចូលបន្ថែមថ្មី | **កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល**<br><br>២០.៤ អភិបាលអាចចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលតាមរយៈសន្និសីទទូរគមនាគមន៍ អេឡិចត្រូនិក ឬ មធ្យោបាយ<br><br>ទំនាក់ទំនងផ្សេងទៀតដែលសម្រួលឱ្យអ្នកចូលរួមទាំងអស់អាចទាក់ទងគ្នាក្នុងពេលតែមួយនិងរហ័ស។ បុគ្គលម្នាក់ដែលចូលរួមនៅក្នុងកិច្ចប្រជុំតាមសន្និសីទអេឡិចត្រូនិក ឬមធ្យោបាយទំនាក់ទំនងផ្សេងទៀតត្រូវចាត់ទុកជាវត្តមានផ្ទាល់ដោយបុគ្គលនៅក្នុងកិច្ចប្រជុំនោះនឹងត្រូវបានរាប់ |

# PESTECH

| | | |
|---|---|---|
| | | ចូលក្នុងក្រុម ទោះបីជាគាត់ពុំមានវត្តមានផ្ទាល់នៅកន្លែងប្រជុំក៏ដោយ។ |
| ២៩ | **គណៈកម្មាធិការចាត់តាំង**<br>២៩.១ គណៈកម្មាធិការចាត់តាំងគណៈកម្មាធិការនេះត្រូវមានសមាជិកយ៉ាងហោចណាស់ បី (០៣) រូប ដែលពួកគាត់ទាំងអស់នេះគឺមិនមែនជាអភិបាលប្រតិបត្តិដែលយ៉ាងហោចណាស់អភិបាល មួយ (០១) រូប ជាអភិបាលឯករាជ្យ។<br>២៩.៣ គណៈកម្មាធិការចាត់តាំងក៏អាចដាក់បញ្ចូលការទទួលខុសត្រូវសម្រាប់ការកំណត់ ឬការពិនិត្យមើលឡើងវិញ និងការផ្តល់អនុសាសន៍អំពីការបង់អត្ថប្រយោជន៍ និងលាភការរបស់អភិបាល និងមន្រ្តីជាន់ខ្ពស់ផងដែរ។<br>២៩.៤ អនុលោមតាមប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយ បុគ្គលិកជាន់ខ្ពស់សំដៅដល់ប្រធានផ្នែករហូតដល់នាយកប្រតិបត្តិ ឬមុខតំណែងប្រហាក់ប្រហែលរួមទាំងលេខាធិការក្រុមហ៊ុន និងប្រធានសវនកម្មផ្ទៃក្នុង និងមុខតំណែងផ្សេងទៀតដែលកំណត់ដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។ | **គណៈកម្មាធិការចាត់តាំង និងលាភការ**<br>២៩.១ ក្នុងករណីគណៈកម្មាធិការចាត់តាំង **និងលាភការ** ត្រូវមានសមាជិកយ៉ាងតិចបី (៣) រូប ដែលពួកគាត់ទាំងអស់នេះជាអភិបាលមិនប្រតិបត្តិ។<br>២៩.៣ គណៈកម្មាធិការចាត់តាំង **និងលាភការ** ក៏អាចរួមបញ្ចូលនូវការទទួលខុសត្រូវក្នុងការកំណត់ ឬពិនិត្យ និងផ្តល់អនុសាសន៍អំពីសំណង និងប្រាក់ឈ្នួលរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ផងដែរ |
| ៣៣ | **សន្និបាត**<br>ការបញ្ចូលបន្ថែមថ្មី | **សន្និបាត**<br>**៣៣.៤ ភាគហ៊ុនិកអាចចូលរួមក្នុងកិច្ចប្រជុំមហាសន្និបាតនៅសាលប្រជុំច្រើនជាងមួយ** |

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក (លេខចុះបញ្ជី៖ ០០០០០៩៥៧)
(ក្រុមហ៊ុន PESTECH)
ផ្ទះលេខ ០៦ ផ្លូវ ៥៨៨ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨២ ១០៥ ទូរសារ +៨៥៥ ២៣ ៨៨២ ១០៦ គេហទំព័រ៖ www.pestech-international.com

| | | |
|---|---|---|
| | | **(១) ដោយទំនាក់ទំនងតាមរយៈសន្និសីទទូរគមនាគមន៍ អេឡិចត្រូនិក ឬ មធ្យោបាយទំនាក់ទំនងផ្សេងទៀតដែលអាចប្រើប្រាស់បានពីមួយគ្រាទៅមួយគ្រា នាពេលអនាគតដើម្បីសម្រួលឱ្យភាគហ៊ុនិកទាំងអស់អាចចូលរួមក្នុងកិច្ចប្រជុំនូវការប្រាស្រ័យទាក់ទងគ្នាក្នុងពេលប្រជុំនិងរហ័ស និងដើម្បីបោះឆ្នោតនៅក្នុងកិច្ចប្រជុំនេះ។** |
| ៣៤ | **អ្នកតំណាង**<br>៣៤.២ ប្រសិនបើអ្នកតំណាងស្នើសុំបោះឆ្នោតនៅឯកិច្ចប្រជុំលិខិតតុបករណ៍តែងតាំងអ្នកតំណាងរូបនោះត្រូវដាក់ជូនប្រធានក្រុមប្រឹក្សាភិបាលនៅពេល ឬមុនចាប់ផ្ដើមកិច្ចប្រជុំ។ | **អ្នកតំណាង**<br>៣៤.២ ប្រសិនបើអ្នកតំណាងស្នើសុំបោះឆ្នោតនៅឯកិច្ចប្រជុំលិខិតតុបករណ៍តែងតាំងអ្នកតំណាងរូបនោះត្រូវដាក់ជូន**ក្រុមហ៊ុន**មុនចាប់ផ្ដើមកិច្ចប្រជុំ។ |
| ៣៥ | **សេចក្ដីជូនដំណឹងអំពីមហាសន្និបាត**<br>សេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬតាមមធ្យោបាយអេឡិចត្រូនិកអំពីកិច្ចប្រជុំនីមួយៗរបស់ម្ចាស់ភាគហ៊ុនដែលមានចុះកាលបរិច្ឆេទពេលវេលា និងទីកន្លែងព្រមទាំងគោលបំណង (សំរាប់កិច្ចប្រជុំពិសេស) ដែលកោះអោយមានកិច្ចប្រជុំនេះត្រូវផ្ដល់ជូនយ៉ាងតិចម្ភៃ (២០) ថ្ងៃ ជាមុនតែមិនត្រូវលើសពីហាសិប (៥០) ថ្ងៃ មុនកាលបរិច្ឆេទប្រជុំទៅម្ចាស់ភាគហ៊ុននីមួយៗដែលមានក្នុងកំណត់ត្រាតាមអាសយដ្ឋានដែលមានដាក់ក្នុងកំណត់ត្រាថ្មីរបស់ម្ចាស់ភាគហ៊ុននៃក្រុមហ៊ុន។ | **សេចក្ដីជូនដំណឹងអំពីមហាសន្និបាត**<br>សេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬតាមមធ្យោបាយអេឡិចត្រូនិកអំពីកិច្ចប្រជុំនីមួយៗរបស់ម្ចាស់ភាគហ៊ុនដែលមានចុះកាលបរិច្ឆេទពេលវេលា និងទីកន្លែងព្រមទាំងគោលបំណង (សំរាប់កិច្ច **សាមញ្ញ និង** កិច្ចប្រជុំពិសេស) ដែលកោះអោយមានកិច្ចប្រជុំនេះត្រូវផ្ដល់ជូនយ៉ាងតិចម្ភៃ (២០) ថ្ងៃ ជាមុនតែមិនត្រូវលើសពីហាសិប (៥០) ថ្ងៃ មុនកាលបរិច្ឆេទប្រជុំទៅម្ចាស់ភាគហ៊ុននីមួយៗ ដែលមានក្នុងកំណត់ត្រាតាមអាសយដ្ឋានដែល |

| | | |
|---|---|---|
| | | មានដាក់ក្នុងកំណត់ត្រាថ្មីរបស់ម្ចាស់ភាគហ៊ុននៃក្រុមហ៊ុន។ |
| ៣៩ | **កាលបរិច្ឆេទកំណត់ត្រា និងសៀវភៅផ្ទេរភាគហ៊ុន**<br>៣៩.១ សំរាប់គោលបំណងកំណត់ម្ចាស់ភាគហ៊ុនដែលមានសិទ្ធិទទួលសេចក្តីជូនដំណឹងអំពីឬមានសិទ្ធិបោះឆ្នោតនៅឯកិច្ចប្រជុំណាមួយរបស់ម្ចាស់ភាគហ៊ុន ឬអំពីការលើកពេលប្រជុំណាមួយ ឬដែលមានសិទ្ធិទទួលនូវការទូទាត់ភាគលាភ ឬក្នុងគោលបំណងកំណត់ម្ចាស់ភាគហ៊ុនសំរាប់គោលបំណងផ្សេងណាមួយក្រុមប្រឹក្សាភិបាលអាចកំណត់ជាមុននូវកាលបរិច្ឆេទកំណត់ត្រាសំរាប់ការកំណត់ម្ចាស់ភាគហ៊ុនបែបនេះដែលកាលបរិច្ឆេទនេះមិនត្រូវលើសពីហាសិប (៥០) ថ្ងៃ ហើយបើជាកិច្ចប្រជុំម្ចាស់ភាគហ៊ុនវិញនោះមិនត្រូវតិចជាងម្ភៃ (២០) ថ្ងៃឡើយមុនកាលបរិច្ឆេទដែលចំណាត់ការពិសេស (តម្រូវអោយមានការសម្រេចចិត្តពីម្ចាស់ភាគហ៊ុន) ត្រូវបានចាត់ធ្វើឡើង។ | **កាលបរិច្ឆេទកំណត់ត្រា និងសៀវភៅផ្ទេរភាគហ៊ុន**<br>៣៩.១ សំរាប់គោលបំណងកំណត់ម្ចាស់ភាគហ៊ុនដែលមានសិទ្ធិទទួលសេចក្តីជូនដំណឹងអំពីឬមានសិទ្ធិបោះឆ្នោតនៅឯកិច្ចប្រជុំណាមួយរបស់ម្ចាស់ភាគហ៊ុន ឬអំពីការលើកពេលប្រជុំណាមួយ ឬដែលមានសិទ្ធិទទួលនូវការទូទាត់ភាគលាភ ឬក្នុងគោលបំណងកំណត់ម្ចាស់ភាគហ៊ុនសំរាប់គោលបំណងផ្សេងណាមួយក្រុមប្រឹក្សាភិបាលអាចកំណត់ជាមុននូវកាលបរិច្ឆេទកំណត់ត្រាសំរាប់ការកំណត់ម្ចាស់ភាគហ៊ុនបែបនេះ **អនុលោមតាមប្រកាស និង/ឬបញ្ញត្តិផ្សេងៗ ឬសេចក្តីណែនាំដែលចេញដោយ នមក ឬ ផមក** ហើយបើជាកិច្ចប្រជុំម្ចាស់ភាគហ៊ុនវិញនោះមិនត្រូវតិចជាង ម្ភៃ (២០) ថ្ងៃឡើយមុនកាលបរិច្ឆេទដែលចំណាត់ការពិសេស (តម្រូវអោយមានការសម្រេចចិត្តពីម្ចាស់ភាគហ៊ុន) ត្រូវបានចាត់ធ្វើឡើង។ |
| ៤០ | **កំណត់ត្រាបោះឆ្នោត**<br>ការបញ្ចូលបន្ថែមថ្មី | **កំណត់ត្រាបោះឆ្នោត**<br>៤០.២ **វិធីនៃការបោះឆ្នោតរួមមានការប្រើប្រាស់សន្លឹកឆ្នោត ឬក្រដាសឆ្នោត សំបុត្រអេឡិចត្រូនិកដោយប្រើប្រាស់ទម្រង់ឧបករណ៍បោះឆ្នោតអេឡិចត្រូនិកផ្សេងៗ** |

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក (លេខចុះបញ្ជី៖ ០០០០០៩៥៧)
(ក្រុមហ៊ុន PESTECH)
ផ្ទះលេខ ០៦ ផ្លូវ ៥៨៨ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨២ ១០៥ ទូរសារ +៨៥៥ ២៣ ៨៨២ ១០៦ គេហទំព័រ៖ www.pestech-international.com

| | | |
|---|---|---|
| | | ហើយលទ្ធផលនៃការបោះឆ្នោតត្រូវចាត់ទុកថាជាសេចក្តីសម្រេចនៃកិច្ចប្រជុំ។ |
| ៤៣ | **សេចក្តីសម្រេចពិសេស**<br>៤៣.១ ទោះបីជាមានប្រការ ៤២ ខាងលើនេះក៏ដោយ រាល់សេចក្តីសម្រេចពិសេសរបស់ម្ចាស់ភាគហ៊ុនត្រូវមានសន្លឹកឆ្នោតវិជ្ជមានពីរភាគបី (២/៣) នៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតដែលកាន់កាប់ដោយបណ្តាម្ចាស់ភាគហ៊ុន និងអ្នកតំណាងដែលមានវត្តមាននៅឯកិច្ចប្រជុំនោះ។ គ្មានសេចក្តីសម្រេចពិសេសណាមួយត្រូវភ្ជាប់កាតព្វកិច្ចលើក្រុមហ៊ុនបានឡើយ វៀរលែងតែត្រូវបានអនុម័តតាមរបៀបខាងលើនេះ។<br>៤៣.២ បញ្ហាផ្សេងៗដូចខាងក្រោមនេះតម្រូវឱ្យមានសេចក្តីសម្រេចពិសេសមួយពីម្ចាស់ភាគហ៊ុនមានន័យថាជាសេចក្តីសម្រេចមួយដែលត្រូវបានអនុម័តដោយសម្លេងភាគច្រើនមិនតិចជាង ពីរភាគបី (២/៣) នៃសម្លេងឆ្នោតរបស់ម្ចាស់ភាគហ៊ុនដែលបានបោះឆ្នោតលើសេចក្តីសម្រេចពិសេសនោះ ឬជាសេចក្តីសម្រេចមួយដែលត្រូវបានចុះហត្ថលេខាដោយម្ចាស់ភាគហ៊ុនទាំងអស់ដែលមានសិទ្ធិបោះឆ្នោតលើសេចក្តីសម្រេចពិសេសនោះ **("សេចក្តីសម្រេចពិសេស")**៖<br>(i) ការផ្លាស់ប្តូរនាមករណ៍របស់ក្រុមហ៊ុន | **សេចក្តីសម្រេចពិសេស**<br>៤៣.១ ~~ទោះបីជាមានប្រការ ៤២ ខាងលើនេះក៏ដោយ រាល់សេចក្តីសម្រេចពិសេសរបស់ម្ចាស់ភាគហ៊ុន ត្រូវមានសន្លឹកឆ្នោតវិជ្ជមាន ពីរភាគបី (២/៣) នៃភាគហ៊ុនដែលមាន សិទ្ធិបោះឆ្នោតដែលកាន់កាប់ដោយបណ្តាម្ចាស់ភាគហ៊ុន និងអ្នកតំណាងដែលមាន វត្តមាននៅឯកិច្ចប្រជុំនោះ។ គ្មានសេចក្តីសម្រេចពិសេសណាមួយត្រូវភ្ជាប់កាតព្វកិច្ចលើក្រុមហ៊ុនបានឡើយ វៀរលែងតែត្រូវបានអនុម័តតាមរបៀបខាងលើនេះ។~~<br>៤៣.២ បញ្ហាផ្សេងៗដូចខាងក្រោមនេះតម្រូវឱ្យមានសេចក្តីសម្រេចពិសេសមួយពីម្ចាស់ភាគហ៊ុនមានន័យថាជាសេចក្តីសម្រេចមួយដែលត្រូវបានអនុម័តដោយសម្លេងភាគច្រើនមិនតិចជាង ពីរភាគបី (២/៣) នៃសម្លេងឆ្នោតរបស់ម្ចាស់ភាគហ៊ុនដែលបានបោះឆ្នោតលើសេចក្តីសម្រេចពិសេសនោះ ឬជាសេចក្តីសម្រេចមួយដែលត្រូវបានចុះហត្ថលេខាដោយម្ចាស់ភាគហ៊ុនទាំងអស់ដែលមានសិទ្ធិបោះឆ្នោតលើសេចក្តីសម្រេចពិសេសនោះ **("សេចក្តីសម្រេចពិសេស")**៖ |

| | | |
|---|---|---|
| | (ii) ការកែប្រែដើមទុនដែលត្រូវបានចុះបញ្ជីយ៉ាងត្រឹមត្រូវរបស់ក្រុមហ៊ុន<br>(iii) ការអនុម័តយល់ព្រមលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការរំលាយក្រុមហ៊ុន<br>(iv) ការបង្កើន ការបន្ថយ ឬការកែប្រែ ទាក់ទងនឹងកម្មវត្ថុអាជីវកម្ម គោលបំណង ឬកិច្ចការរបស់ក្រុមហ៊ុន<br>(v) ការបែងចែកសាជាថ្មីនូវចំនួនភាគហ៊ុនជាថ្នាក់ណាមួយឡើងវិញដោយមានការកែប្រែលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់ថ្នាក់ភាគហ៊ុនពិសេសណាមួយ<br>(vi) ការកែប្រែភាគលាភដែលត្រូវទូទាត់ដល់ប្រភេទភាគហ៊ុនណាមួយ<br>(vii) ការបង្កើនដើមទុនដោយបង្កើតភាគហ៊ុនប្រភេទថ្មីដែលមានលក្ខណៈដាច់ខាត និងមិនដាច់ខាតខ្ពស់ជាង ឬទាបជាងថ្នាក់ភាគហ៊ុនដែលមានរួចហើយ<br>(viii) ការបន្ថយដើមទុនចុះបញ្ជីដោយបញ្ចុះតំលៃចារឹកលើប័ណ្ណនៃប្រភេទ ឬស៊េរីភាគហ៊ុនណាមួយ ឬដោយបន្ថយចំនួនភាគហ៊ុនដែលមានសិទ្ធិរបស់ក្រុមហ៊ុន<br>(ix) ការកែប្រែចិរវេលាអត្ថិភាពរបស់ក្រុមហ៊ុន<br>(x) ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន | (i) ការផ្លាស់ប្តូរនាមករណ៍របស់ក្រុមហ៊ុន<br>(ii) ការកែប្រែដើមទុនដែលត្រូវបានចុះបញ្ជីយ៉ាងត្រឹមត្រូវរបស់ក្រុមហ៊ុន<br>(iii) ការអនុម័តយល់ព្រមលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការរំលាយក្រុមហ៊ុន<br>(iv) ការបង្កើន ការបន្ថយ ឬការកែប្រែ ទាក់ទងនឹងកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន<br>(v) ការបែងចែកសាជាថ្មីនូវចំនួនភាគហ៊ុនជាថ្នាក់ណាមួយឡើងវិញដោយមានការកែប្រែលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់ថ្នាក់ភាគហ៊ុនពិសេសណាមួយ<br>(vi) ការកែប្រែភាគលាភដែលត្រូវទូទាត់ដល់ប្រភេទភាគហ៊ុនណាមួយ<br>(vii) ការបង្កើនដើមទុនដោយបង្កើតភាគហ៊ុនប្រភេទថ្មីដែលមានលក្ខណៈដាច់ខាត និងមិនដាច់ខាតខ្ពស់ជាង ឬទាបជាងថ្នាក់ភាគហ៊ុនដែលមានរួចហើយ<br>(viii) ការបន្ថយដើមទុនចុះបញ្ជីដោយបញ្ចុះតំលៃចារឹកលើប័ណ្ណនៃប្រភេទ ឬស៊េរីភាគហ៊ុនណាមួយ ឬដោយបន្ថយចំនួនភាគហ៊ុនដែលមានសិទ្ធិរបស់ក្រុមហ៊ុន<br>(ix) ការកែប្រែចិរវេលាអត្ថិភាពរបស់ក្រុមហ៊ុន |

PESTECH

| | | |
|---|---|---|
| | (xi) ការកែប្រែលក្ខខណ្ឌកូរ៉ុម សំរាប់សន្និបាតនៃម្ចាស់ហ៊ុន ឬសំរាប់ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល និង<br>(xii) តាមការតំរូវផ្សេងៗទៀតដោយលក្ខន្តិកៈនេះ។ | (x) ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន<br>(xi) ការកែប្រែលក្ខខណ្ឌកូរ៉ុមសំរាប់សន្និបាតនៃម្ចាស់ហ៊ុន ឬសំរាប់ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល និង<br>(xii) តាមការតំរូវផ្សេងៗទៀតដោយលក្ខន្តិកៈនេះ។ |
| ៤៨ | **សេចក្តីជូនដំណឹងអំពីភាគលាភ**<br>សេចក្តីជូនដំណឹងអំពីភាគលាភណាមួយដែលអាចត្រូវបានប្រកាសត្រូវប្រគល់ជូនជាលិខិតជូនដំណឹងដល់បណ្តាម្ចាស់ភាគហ៊ុន។ | **សេចក្តីជូនដំណឹងអំពីភាគលាភ**<br>សេចក្តីជូនដំណឹងអំពីភាគលាភណាមួយដែលអាចត្រូវបានប្រកាសត្រូវប្រគល់ជូនជាលិខិតជូនដំណឹង **ឬតាមមធ្យោបាយអេឡិចត្រូនិកណាមួយ**ដល់បណ្តាម្ចាស់ភាគហ៊ុន។ |

**សម្គាល់៖**

១. ភាគហ៊ុននិកមានឈ្មោះក្នុងបញ្ជីភាគហ៊ុនិកដែលបានកត់ត្រានៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២១ នឹងទទួលបានការអញ្ជើញតាមរយៈមធ្យោបាយអេឡិចត្រូនិក ឬតាមរយៈភ្នាក់ងារផ្ទេរមូលបត្រដែលបានតែងតាំង។

២. បន្ទាប់ពីទទួលបានការអញ្ជើញដូចបានជម្រាបជូនខាងលើ ភាគហ៊ុនិកត្រូវបញ្ជាក់ពីការចូលរួមរបស់ខ្លួនទៅកាន់ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** តាមរយៈមធ្យោបាយអេឡិចត្រូនិក ឬតាមរយៈភ្នាក់ងារផ្ទេរមូលបត្ររបស់ខ្លួនចាប់ពី ថ្ងៃពុធ ទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ដល់ ថ្ងៃពុធ ទី៨ ខែធ្នូ ឆ្នាំ២០២១។

៣. ក្នុងករណីដែលភាគហ៊ុនិកណាម្នាក់ពុំអាចចូលរួមកិច្ចប្រជុំមហាសន្និបាតដោយផ្ទាល់ទេនោះ ភាគហ៊ុនិករូបនោះអាចតែងតាំងបុគ្គលណាម្នាក់ផ្សេងទៀតអោយធ្វើជាអ្នកតំណាងរបស់ខ្លួនដើម្បីចូលរួមកិច្ចប្រជុំនោះបាន។

៤. ឯកសារបែបបទរបស់អ្នកតំណាងនឹងត្រូវផ្ញើជូនភាគហ៊ុនិកជាមួយ និងសេចក្តីជូនដំណឹងស្តីពីកិច្ចប្រជុំមហាសន្និបាត។ ភាគហ៊ុនិក ឬអ្នកតំណាងត្រូវផ្ញើឯកសារបែបបទរបស់អ្នកតំណាងនោះទៅ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** អោយបានត្រឹម ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២១ តាមរយៈមធ្យោបាយអេឡិចត្រូនិច ឬតាមរយៈភ្នាក់ងារផ្ទេរមូលបត្រដែលខ្លួនបានតែងតាំង។

**ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក** (លេខចុះបញ្ជី៖ ០០០០០៩៥៧)

(ក្រុមហ៊ុន PESTECH)

ផ្ទះលេខ ០៦ ផ្លូវ ៥៨៨ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨២ ១០៥ ទូរសារ +៨៥៥ ២៣ ៨៨២ ១០៦ គេហទំព័រ៖ www.pestech-international.com

PESTECH

៥ ភាគហ៊ុននិកដែលពុំបានបញ្ជាក់អំពីការអញ្ជើញចូលរួម ឬពុំបានផ្តល់ឯកសារបែបបទអ្នកតំណាងដល់ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** ឬភ្នាក់ងារផ្ទេរមូលបត្រតាមកាលបរិច្ឆេទកំណត់ខាងលើនឹងមិនត្រូវបាន អនុញ្ញាតឱ្យចូលរួមកិច្ចប្រជុំមហាសន្និបាតរបស់ ផថខ ឡើយ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកកាន់ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** ឬ **ផថខ** ដូចខាងក្រោម៖


**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

**លោក លឹម អាន** ប្រធានផ្នែកប្រតិបត្តិការ RTP
ទូរស័ព្ទ៖ (៨៥៥) ១៥ ៦០០ ៧៤៣
អ៊ីម៉ែល៖ lim.an@acledabank.com.kh

**លោក ហួត សុភី** អនុប្រធានផ្នែកប្រតិបត្តិការ RTP និង ជំនួយការ អ្នកគ្រប់គ្រង RTP
ទូរស័ព្ទ៖ (៨៥៥) ១៥ ៩០០ ៥៣៨
អ៊ីម៉ែល៖ huot.sophy@acledabank.com.kh

**ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក**

**លោកស្រី វ៉ា សាមឿន** លេខាធិកាក្រុមហ៊ុន
ទូរស័ព្ទ៖ (៨៥៥) ១៥ ៤៨៨ ៤៤៤
អ៊ីម៉ែល៖ samoeun@pestech.com.kh